ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

អគ្គលេខាធិការដ្ឋាន

លេខ : ១៩៣/ល.ខ.ក អ.ជ.ប.គ.ញ
១១

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ ២០១១

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ វិច្ឆិកា ឆ្នាំ ២០១១

## និង ទិសដៅការងារ ខែ ធ្នូ ឆ្នាំ ២០១១

(គិតចាប់ពីថ្ងៃទី ២៦/១០/២០១១ ដល់ ថ្ងៃទី ២៥/១១/២០១១)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្រ្តពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សា សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១១នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែវិច្ឆិកានេះ ក្រុមឈ្មួញគ្រឿងញៀននៃប្រទេសជិតខាងបានបន្តនាំគ្រឿងញៀនសំយោគប្រភេទ **មេតំហ្វេតាមីនគ្រាប់** (អក្សរ WY) និង **មេតំហ្វេតាមីនទឹកកក** (ICE) ចូលមកក្នុងប្រទេសតាមច្រកនៃខេត្តព្រំដែនភាគពាយ័ព្យ ។ ជាក់ស្តែង នៅច្រកទ្វារអន្តរជាតិ ដុងក្រឡ ខេត្តស្ទឹងត្រែង សមត្ថកិច្ចបង្ក្រាបការចរាចរគ្រឿងញៀនប្រភេទមេតំហ្វេតាមីនគ្រាប់ (អក្សរWY) ដែលនាំឆ្លងកាត់ព្រំដែនប្រទេសឡាវចូលមកកម្ពុជាបាន ១ ករណី និងឃាត់ខ្លួនស្រ្តីជនជាតិឡាវមួយនាក់ ។ ដោយឡែក បណ្តាញរបស់ក្រុមឈ្មួញគ្រឿងញៀនកោះតៃវ៉ាន់ នៅក្នុងពេលដែលសមត្ថកិច្ចជាប់រវល់ការពារបុណ្យជាតិសំខាន់ៗមួយចំនួន បានឆ្លៀតឱកាសធ្វើសកម្មភាពជួញដូរគ្រឿងញៀននៅក្នុងភូមិសាស្រ្តរាជធានីភ្នំពេញ តែត្រូវកងរាជអាវុធហត្ថបង្ក្រាបបានទាន់ពេលវេលា ដោយបានឃាត់ខ្លួនជនតៃវ៉ាន់ចំនួន ៩ នាក់ ក្នុងនោះជាស្ត្រី ២ នាក់ ។ យើងក៏បានកត់សំគាល់ឃើញផងដែរថា មាន ១ ករណី ជនល្មើសបានប្រើប្រាស់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធដើម្បីធ្វើសកម្មភាព តែត្រូវបានកងកម្លាំងនៃអគ្គស្នងការដ្ឋាននគរបាលជាតិបង្ក្រាបនិងចាប់យកវត្ថុតាងគ្រឿងញៀនប្រភេទមេតំហ្វេតាមីនទឹកកក(ICE)ជិតមួយគីឡូក្រាម ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ខែវិច្ឆិកានេះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និងណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ខ្លឹមសារដឹកនាំនិងណែនាំមាននៅក្នុងឧបសម្ព័ន្ធ) ។ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អាជ្ញាធរជាតិបានខិតខំអនុវត្តទទួលបានលទ្ធផលដូចខាងក្រោម :

### ១. *កាត់បន្ថយតម្រូវការគ្រឿងញៀន*

#### ១.១. *សកម្មភាពអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ* *រួមាន :*

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** សហការសម្របសម្រួលជាមួយក្រសួងព័ត៌មាន ស្ថានីយ វិទ្យុ-ទូរទស្សន៍ រដ្ឋ និងឯកជន ដើម្បីបង្កើនលើការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងពិធីបុណ្យជាតិសំខាន់ៗ ។
- **ក្រសួងមហាផ្ទៃ** តាមរយៈកម្មវិធីសន្តិសុខមាតុភូមិ បានបន្តការផ្សព្វផ្សាយស្ព័តអប់រំបង្ការការប្រើប្រាស់គ្រឿងញៀនតាមកម្មវិធីប្រចាំថ្ងៃរបស់ស្ថានីយទូរទស្សន៍នានា ។
- **ក្រសួងព័ត៌មាន** បានបន្តជំរុញក្រុមសិល្បករ ពិធីករ តន្ត្រីករ តាមបណ្តាស្ថានីយវិទ្យុ-ទូរទស្សន៍រដ្ឋ និង ឯកជនឱ្យបង្កើនសកម្មភាពផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។
- **ក្រសួងកិច្ចការនារី** បានបន្តជំរុញការផ្សព្វផ្សាយអប់រំ ស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងសារសំខាន់នានា ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់គ្រឿងញៀន តាមវិទ្យុនិងទូរទស្សន៍ ។
- **ក្រសួងធម្មការនិងសាសនា** បានបន្តការអនុវត្តកម្មវិធីសន្ទនាព្រះធម៌ តាមរយៈនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម ដើម្បីលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហិង្សា ។
- **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** បានបន្តណែនាំដល់ផលិតកម្មភាពយន្ត-វីដេអូ និងក្រុមហ៊ុន នាំចូល-នាំចេញ ខ្សែភាពយន្ត-វីដេអូ ឱ្យដាក់ **សារ** អប់រំពីគ្រឿងញៀននៅលើផលិតផលនៃផលិតកម្មរបស់ខ្លួន ។
- **ក្រសួងទេសចរណ៍** បានបន្តចាក់ផ្សាយ Spot "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" ជាភាសាខ្មែរ-ភាសាបរទេស តាមទូរទស្សន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅតាមទូរទស្សន៍បរទេស រួមទាំងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ" ដែលមានបង្កប់សារអប់រំពីបញ្ហាគ្រឿងញៀន ។

**ដោយឡែក** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តមណ្ឌលគិរី បានផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN តាមកម្មវិធីប្រចាំខែ ស្តីពីលទ្ធផលការងារ និងការទទួលខុសត្រូវលើការងារត្រួតពិនិត្យគ្រឿងញៀនខេត្ត ។

#### ១.២. *សកម្មភាពផ្សព្វផ្សាយអប់រំតាមសហគមន៍ជាតិ :*

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បានរៀបចំពិព័រណ៍រូបភាព និងសារអប់រំពីគ្រឿងញៀន នៅក្នុងឱកាសបុណ្យខួបទី ២០ ឆ្នាំ នៃការយាងនិវត្តន៍មកកាន់មាតុប្រទេសរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ, ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មថ្វាយព្រះអង្គគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា, ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតកងយោធពលខេមរភូមិន្ទ ។
- បានធ្វើការកែសម្រួលផ្ទាំងរូបភាព (រូបសម្តេចនាយករដ្ឋមន្ត្រីដុតកម្ទេចដំណាំកញ្ឆា) និងបន្ថែមរូបភាពលោកជំទាវ

កិត្តិព្រឹទ្ធបណ្ឌិត និងសារអប់រំពីបញ្ហាគ្រឿងញៀន ដែលបច្ចុប្បន្នតាំងនៅខាងលិចគល់ស្ពានជ្រោយចង្វា ។

- បានចូលរួមផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀននៅក្នុងរយៈពេលថ្ងៃបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក តាមរយៈការចងបដាពាក្យស្លោកអប់រំបង្ការគ្រឿងញៀន, ការប្រគំតន្ត្រី, ការបញ្ចាំង Spot Video ចល័តតាមរថយន្ត, ការរៀបចំក្បួនដើរផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀនដោយក្រុមយុវជនស្ម័គ្រចិត្តកាកបាទក្រហមកម្ពុជា និងក្រុមកាយឫទ្ធិ និងការចែកខិត្តបណ្ណ័ផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន នៅតាមតំបន់គោលដៅមួយចំនួនក្នុងរាជធានីភ្នំពេញ ។
- បានបើកវគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន រយៈពេល២ថ្ងៃ(២៤/២៥/១១/២០១១) ដល់ប្រធាន/អនុប្រធានលេខាធិការគ្រឿងញៀន, ប្រធាន/អនុប្រធានមន្ទីរអប់រំយុវជននិងកីឡារាជធានី-ខេត្ត, នាយក នាយករងវិទ្យាល័យនៃរាជធានី-ខេត្ត នានា និងមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ (សរុបចំនួន ២00នាក់) ។
- **ក្រសួងទេសចរណ៍**
  - បានបន្តជំរុញឱ្យមន្ទីរទេសចរណ៍រាជធានី-ខេត្ត អនុវត្តតាមស្មារតីអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ ដែលមានបង្កប់សារអប់រំពីបញ្ហាគ្រឿងញៀន ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឱ្យបិទផ្សាយនូវបណ្ណ័ផ្សព្វផ្សាយអំពីគ្រឿងញៀន អេដស៍ ការជួញដូរមនុស្ស និងការជួញដូរអាវុធជាតិផ្ទុះ នៅតាមគោលដៅសេវាកម្មទេសចរណ៍ (ផ្ទះសំណាក់, សណ្ឋាគារ កន្លែងកម្សាន្ត នានា) ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត សហការជាមួយសមាគមសណ្ឋាគារ សេវាស្នាក់នៅទេសចរណ៍ សមាគមដឹកជញ្ជូនទេសចរណ៍ សេវាក្លឹបកម្សាន្តទេសចរណ៍ ម៉ាស្សា ខារ៉ាអូខេ ដើម្បីចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀននៅតាមមូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ និងតាមរយៈការបញ្ច្រាបយេនឌ័រ នៅខេត្តតំបន់ឆ្នេរសមុទ្រ រួមមាន ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប ដល់ប្រតិបត្តិករទេសចរណ៍ និង បុគ្គលិកបម្រើសេវាកម្មទេសចរណ៍ ។
- **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម** បានបន្តជំរុញវិស័យឯកជនអនុវត្តការបិទសារអប់រំពីផលប៉ះពាល់នៃគ្រឿងញៀន នៅលើផលិតផលភេសជ្ជៈ ម្ហូបអាហារ និងផលិតផលផ្សេងៗរបស់ក្រុមហ៊ុនខ្លួន ។
- **ក្រសួងសាធារណការនិងដឹកជញ្ជូន** បានបន្តសហការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក(មាត្រា ៧៥ ពាក់ពន្ធ័នឹងការធ្វើតេស្តជាតិអាកុលនិងគ្រឿង ញៀន) និងបន្តអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រកបអាជីវកម្មផ្លូវថ្នល់ (មាត្រា ១២ ពាក់ពន្ធ័នឹងការហាម ឃាត់ការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់ ទំនិញមានក្លិនអាក្រក់ ទំនិញដែលរដ្ឋហាមឃាត់ ដូចជា គ្រឿងញៀន ជាដើម) ។

សកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់នៅតាមសហគមន៍របស់ក្រសួង-ស្ថាប័ន ដែលមានការពាក់ពន្ធ័ រួមទាំងសកម្មភាព

ផ្សព្វផ្សាយអប់រំជាប្រចាំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៧ (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ) មានអ្នកចូលរួមសរុបចំនួន ***១៧.១១០*** នាក់ ។

## ***២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ខែវិច្ឆិកានេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ***២.១. ការបង្ក្រាបបទល្មើសគ្រឿងញៀន***

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៣១** ករណី / លើ ៤៦ ករណី ប្រៀបធៀប ខែតុលា ឆ្នាំ២០១១ ថយចុះ ៣២,៦០ % ។

**-ជនសង្ស័យ** ឃាត់ខ្លួនចំនួន **៧៨** នាក់ / លើ ១០២ នាក់ ប្រៀបធៀប ខែតុលាឆ្នាំ២០១១ ថយចុះ ២៣,៥២ % ។ ក្នុងនោះ ចាប់តាមដីកា(ជនជាតិខ្មែរ ៤ នាក់ / ស្រី ២ នាក់) ឃាត់ខ្លួនក្នុងករណីល្មើសគ្រឿងញៀន(៧៤ នាក់ / ស្រី ១៥ នាក់) រួមមាន ជនជាតិ ខ្មែរ ៧២ នាក់(ស្រី ១០ នាក់), វៀតណាម ៥ នាក់(ស្រី ៤ នាក់), ឡាវ ១ នាក់ (ស្រី) ។ ជនសង្ស័យទាំងអស់ ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។

**-វត្ថុតាងគ្រឿងញៀនសំខាន់ៗ** រួមមាន :

មេតំហ្វេតាមីនគ្រាប់(អក្សរ WY) ៦.២៦៨ គ្រាប់, មេតំហ្វេតាមីនទឹកកក(Ice) ១.៣៧១,៨៣ ក្រាម ។

**-ទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនសំខាន់ៗ** រួមមាន :

ប្រាក់ ២៤០.០០០ រៀល, រថយន្ត៥គ្រឿង, ម៉ូតូ១០គ្រឿងនិងវត្ថុតាងផ្សេងទៀត មានរាយក្នុងតារាងឧបសម្ព័ន្ធ ។

### ***២.២. ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង***

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងក្នុងខែវិច្ឆិកានេះ បានចំនួន ៦១ សំណាក ក្នុង ៤៤ ករណី ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** មាន **៧ សំណាក = ១១ %** និងសំណាក **វិជ្ជមានសារធាតុញៀន ៥៤ សំណាក = ៨៩ %** គឺ៖

-មេតំហ្វេតាមីនទឹកកក (Ice) ៣២ សំណាក = ៥២ %
-មេតំហ្វេតាមីនគ្រាប់ ១៥ សំណាក = ២៤ %
-កូដេអ៊ីន ១ សំណាក = ២ %
-កេតាមីន ៤ សំណាក = ៧ %
-ហេរ៉ូអ៊ីន ១ សំណាក = ២ %
-MDMA ១ សំណាក = ២ %

### ***២.៣. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងក្រសួងសុខាភិបាល នៅក្នុងខែវិច្ឆិកានេះ សរុបមានចំនួន **៤៥៥.៣៥០** គ.ក្រ (មានរាយមុខសារធាតុគីមីក្នុងតារាងឧបសម្ព័ន្ធ) ។ ក្រៅពីការអនុញ្ញាតឱ្យនាំចូលនូវសារធាតុគីមីផ្សំក្នុងចំនួនខាងលើ ក្រសួងសុខាភិបាលបាននាំចូលសារធាតុប៉ះពាល់

ប្រព័ន្ធសរសៃប្រសាទដែលមានឈ្មោះ Fentanyl, Morphine, Dopamine, Phenobarbital និង សារធាតុគីមីផ្សំ Ephedrine សរុបចំនួន **១០២** Kg និង **១.២៧៦** g និង **១.១០០** mg ( មានរាយមុខសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទនៅក្នុងតារាងឧបសម្ព័ន្ធ) ។

## ៣. ការព្យាបាល / ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

### ៣.១. ការងារព្យាបាល / ស្តារនីតិសម្បទា

ខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.ប.គ បានបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាលក្នុងការបង្កើតសេវាសុខភាពផ្លូវចិត្ត និងគ្រឿងញៀន នៅខេត្តស្ទឹងត្រែង និង ខេត្តក្រចេះ ដើម្បីចូលរួមអនុវត្តផែនការសកម្មភាពរបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនឡាវ ដោយយកគំរូសេវាព្យាបាលដោយផ្អែកលើសហគមន៍ ដូចដែលបាននិងកំពុងអនុវត្តនៅខេត្តបន្ទាយមានជ័យ ។

### ៣.២. ការកាត់បន្ថយគ្រោះថ្នាក់

#### នៅក្នុងប្រទេស

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសម្រេចជាផ្លូវការដាក់ឱ្យប្រើប្រាស់ឯកសារសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន នាថ្ងៃទី ១៦/១១/២០១១ ។

#### អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមកិច្ចប្រជុំក្រុមការងាររួម រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការងារមេរោគអេដស៍/ជំងឺអេដស៍ ( រៀបចំដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍) ។ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើសេចក្តីព្រាងសូចនាករ និងគោលដៅលទ្ធភាពទទួលបានសេវាជាសកល សម្រាប់ឆ្នាំ ២០១៣-២០១៥ ដែលក្នុងនោះ :
  - សូចនាករទី៥ បង្ហាញថាភាគរយនៃអ្នកប្រើប្រាស់គ្រឿងញៀនទទួលបានកម្មវិធីបង្ការទប់ស្កាត់ជំងឺអេដស៍ សម្រាប់ឆ្នាំ២០១០( ៥០%) សម្រាប់គោលដៅឆ្នាំ២០១៣( ៧០ %) និងសម្រាប់គោលដៅឆ្នាំ២០១៥ ( ៨០%) ។
  - សូចនាករទី៦ បង្ហាញថា ភាគរយនៃអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ទទួលបានកម្មវិធីបង្ការទប់ស្កាត់ជំងឺអេដស៍ តាមរយៈកម្មវិធីម្ជុល/ស៊ីរ៉ាំង(NSP) សម្រាប់ឆ្នាំ២០១០( ១៨៦៩នាក់) សម្រាប់គោលដៅឆ្នាំ២០១៣ (៥០%) និងសម្រាប់គោលដៅឆ្នាំ២០១៥ ( ៦០%) ។
  - សូចនាករទី៧ បង្ហាញថា ភាគរយនៃអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ទទួលបានតាមរយៈកម្មវិធីមេតាដូន សម្រាប់ឆ្នាំ២០១០( ៦១នាក់) សម្រាប់គោលដៅឆ្នាំ២០១៣( ៣០%) និងសម្រាប់គោលដៅឆ្នាំ២០១៥ ( ៤០%) ។

- បានចូលរួមពិនិត្យលើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ ក្នុងការឆ្លើយតបចំពោះការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀន សម្រាប់ឆ្នាំ ២០១១-២០១៥ ។ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិ មានយុទ្ធសាស្ត្រសំខាន់ៗចំនួន ៥ គឺ : **ទី១.** ការបង្ការការប្រើបំពានគ្រឿងញៀន និងការឆ្លងមេរោគ អេដស៍, **ទី២.** ការព្យាបាលថែទាំអ្នកញៀនគ្រឿងញៀន និងអ្នកផ្ទុកមេរោគអេដស៍, **ទី៣.** ការបង្កើតបរិយាកាសគាំទ្រ និងការតស៊ូមតិ, **ទី៤.** ការពង្រឹងសមត្ថភាពដល់ដៃគូពាក់ព័ន្ធ ដែលមានសកម្មភាពឆ្លើយតបចំពោះបញ្ហាគ្រឿងញៀន និងអេដស៍, **ទី៥.** ការពង្រឹងសមត្ថភាពតាមដាន និងវាយតម្លៃក្នុងការឆ្លើយតបចំពោះបញ្ហាគ្រឿងញៀន និងអេដស៍ ។
- បានពិនិត្យលើខ្លឹមសារសេចក្តីព្រាងរបាយការណ៍ ស្តីពីលទ្ធផលនៃការពិនិត្យវាយតម្លៃលើសកម្មភាពអនុវត្តកម្មវិធីម្ជុល/ស៊ីរ៉ាំងនៅកម្ពុជា របស់អង្គការ អេ្វស.អេច.អាយ ៣៦០ (FHI 360) ។ តាមការពិនិត្យលើសេចក្តីព្រាងរបាយការណ៍នេះ មានខ្លឹមសារស្ថាបនាច្រើនដែលអាចធ្វើការបោះពុម្ពសម្រាប់ត្រៀមការរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីលទ្ធផលនៃការសិក្សាវាយតម្លៃនេះ ។
- បានចូលរួមក្នុងកិច្ចប្រជុំស្តីពីការកំណត់សូចនាករ និងគោលដៅលទ្ធភាពទទួលបានសេវាជាសាកល ឆ្នាំ២០១៣-២០១៥ ទាក់ទងនឹងសូចនាករ DU/IDU កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

***នៅក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- តាមការអញ្ជើញរបស់សកលវិទ្យាល័យ Adelaide ប្រទេសអូស្ត្រាលី បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១រូប ទៅចូលរួមសិក្ខាសាលាស្តីពីវិធីសាស្ត្រជាក់ស្តែងដែលមានប្រសិទ្ធភាពក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀននៅអាស៊ី ( ថ្ងៃទី១៧-១៩/១០/២០១១) ។ សិក្ខាសាលាបានធ្វើការពិភាក្សាលើប្រធានបទចំនួន ២ គឺ :
  - ការចូលរួមពីសហគមន៍ដើម្បីឱ្យអ្នកញៀនគ្រឿងញៀនទៅទទួលយកសេវាព្យាបាល ។
  - ការត្រួតពិនិត្យនិងវាយតម្លៃនៃការព្យាបាលដោយឱសថដែលមានជាតិអាភៀនដែលផ្អែកលើកត្តាជាក់លាក់ ។

  ឆ្លងតាមរយៈសិក្ខាសាលាតំបន់ខាងលើនេះ កម្ពុជាទទួលបាននូវចំណេះដឹងមួយចំនួន ជាអាទិ៍ ការយល់ដឹងបន្ថែមទៀតពីការប្រឈម និងលទ្ធភាពដោះស្រាយចំពោះកម្មវិធីព្យាបាលដោយឱសថជំនួស ដែលមានជាតិអាភៀន ដោយប្រើឱសថឈ្មោះ Buprenorphine និង Naloxone រួមទាំងកម្មវិធីព្យាបាលដោយឱសថជំនួសនៅក្នុងពន្ធនាគារ, ការយល់ដឹងពីការព្យាករណ៍ចំពោះបញ្ហាជាឧបសគ្គផ្សេងៗ ដែលអាចកើតមានឡើងសម្រាប់អ្នកញៀនហេរ៉ូអ៊ីន, ការយល់ដឹងបន្ថែមទៀតពីអាការៈ នៃការប្រើគ្រឿងញៀនក្នុងរយៈពេលយូរ និងការផ្លាស់ប្តូរការប្រព្រឹត្តប្រកបដោយជោគជ័យ, ការយល់ដឹងពីប្រសិទ្ធភាពជាវិជ្ជមាននៃសេវាបន្ថែម និងបណ្តាញការងារគាំទ្រ ដើម្បីលើកកម្ពស់កម្មវិធីព្យាបាល, ការយល់ដឹងពីវិធីសាស្ត្រក្នុងការផ្តល់ការពិគ្រោះយោបល់ជាក់ស្តែងដែលត្រូវបានប្រើចំពោះអ្នកញៀន ដើម្បីឱ្យគេមកទទួលយកសេវាព្យាបាល, ការយល់ដឹងពីនិន្នាការ និងការឆ្លើយតបបច្ចុប្បន្នក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀននៅក្នុងតំបន់ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានសហការសម្របសម្រួលជាមួយអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់សមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ ជាអាទិ៍ :

***នៅក្នុងប្រទេស :***

***អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣***

- បានបើកវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តត្រួតពិនិត្យគ្រឿងញៀន" នៅខេត្តចំនួន ២ គឺ :
  - ខេត្តបាត់ដំបង ពីថ្ងៃទី ២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១១ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ចំនួន ៤00 នាក់ ។
  - ខេត្តប៉ៃលិន ពីថ្ងៃទី ២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០១១ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ចំនួន ៤00 នាក់ ។
  - បានរៀបចំកិច្ចប្រជុំគណៈកម្មការប្រឹក្សាយោបល់គម្រោង PATROL(PATROL-PAC) របស់អង្គការ UNODC អនុតំបន់(២២-២៣/១១/២០១១) នៅខេត្តកំពង់ចាម ដើម្បីពិភាក្សាគ្នាអំពីការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងនៅក្នុងឆ្នាំ២០១២-២០១៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន នៅកម្ពុជា និងបានចុះទៅពិនិត្យទីតាំងការិយាល័យទំនាក់ទំនងព្រំដែន នៅច្រកទ្វារអន្តរជាតិត្រពាំងផ្លុង(ខេត្តកំពង់ចាម) ដែលទើបបង្កើតក្រោមការគាំទ្ររបស់អង្គការ UNODC អនុតំបន់ ព្រមទាំងធ្វើពិធីប្រគល់ទទួល មធ្យោបាយ និង សម្ភារៈការិយាល័យ សម្រាប់បម្រើឱ្យកិច្ចប្រតិបត្តិការ ។
  - បានបន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្នុងការរៀបចំផែនការសម្រាប់បណ្តុះបណ្តាលលើការងារគ្រប់គ្រងសារធាតុគីមីផ្សំ និងឱសថដែលមានសារធាតុញៀន នៅតាមបណ្តារាជធានី-ខេត្ត ។
  - បាននិងកំពុងបន្តដំណើរការសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានសារធាតុគីមីផ្សំគ្រឿងញៀន នៅខេត្តតាកែវ ខេត្តកំពង់ចាម និង ខេត្តកំពត ។

***អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រសួងមហាផ្ទៃ)***

- បានធ្វើការកែសម្រួលសមាសភាពមន្ត្រីនគរបាល នៃមន្ទីរប្រឆាំងគ្រឿងញៀន ដែលជាសមាជិកប្រចាំការនៅតាមការិយាល័យទំនាក់ទំនងព្រំដែន(BLO) ច្រកទ្វារអន្តរជាតិចំនួន ១០ កន្លែងគឺ ច្រកបាវិត (ខេត្តស្វាយរៀង), ច្រកប៉ោយប៉ែត (ខេត្តបន្ទាយមានជ័យ), ច្រកក្អមសំណ និង ច្រកជ្រៃធំ(ខេត្តកណ្តាល), ច្រកចាំយាម(ខេត្តកោះកុង), ច្រកព្រំ(ខេត្តប៉ៃលិន), ច្រកដូង(ខេត្តបាត់ដំបង), ច្រកកំពង់ស្រឡៅ(ខេត្តព្រះវិហារ), ច្រកត្រពាំងគ្រាល និង ច្រកកោះឈើទាលធំ(ខេត្តស្ទឹងត្រែង) ។

**ដោយឡែក** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកណ្តាល បានចុះពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅស្រុកជាប់ព្រំដែន (ស្រុកកោះធំ និង ស្រុកលើកដែក) និងសមាជិកការិយាល័យទំនាក់ទំនងព្រំដែន (BLO) ក្អមសំណ និងជ្រៃធំ ។

***នៅក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ :*

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើការងារស៊ើបអង្កេតបទឧក្រិដ្ឋអន្តរជាតិ ពីថ្ងៃទី៣១ខែតុលា ដល់ ថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០១១ នៅទីក្រុងឡាអេ ប្រទេសហូឡង់ ដែលមាន

ប្រធានបទសំខាន់ៗ ចំនួន ១២ ក្នុងនោះវគ្គបណ្តុះបណ្តាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការងារស៊ើបអង្កេតបទល្មើសដែលមានចរិត ឬលក្ខណៈជាអន្តរជាតិ រួមមាន ការប្រមូលភស្តុតាង ការធ្វើកោលស្សវិច័យ ការការពារ សាក្សី និងការធ្វើផែនការសម្រាប់ការងារស៊ើបអង្កេត ។

- បានចាត់មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការប្រមូលទិន្នន័យ ការវិភាគ និងធ្វើរបាយការណ៍នយោបាយ និងសកម្មភាព កាលពីថ្ងៃទី១៨-២១ ខែតុលា ឆ្នាំ២០១១ នៅទីក្រុងបាងកក ប្រទេសថៃ ។ គោលបំណងរបស់សិក្ខាសាលាដើម្បីជួយបង្រៀនដល់មន្ត្រីទទួលបន្ទុកបំពេញកម្រងសំណួរប្រចាំឆ្នាំ និងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីចែករំលែកព័ត៌មានពាក់ពន្ធ័នឹងគ្រឿងញៀន និងវិធានការឆ្លើយតបរបស់សាមីប្រទេសនីមួយៗ ព្រមទាំងការពិភាក្សាលើជំហានអនុវត្តបន្តក្នុងកម្មវិធីនេះប្រចាំតំបន់នៅពេលអនាគត ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ទទួលបានលទ្ធផលដូចខាងក្រោម ៖

***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ៖*

- បានរៀបចំទទួលក្រុមប្រតិភូ នៃអគ្គរដ្ឋអាជ្ញាសាធារណរដ្ឋកូរ៉េ ដែលអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ ។ នៅក្នុងឱកាសនោះ ភាគីកម្ពុជា បានធ្វើការបង្ហាញពីខ្លឹមសារគោលសំខាន់ៗមួយចំនួន និងទម្រង់បែបបទស្នើសុំគម្រោងជំនួយជាលើកទី៣ ពីភាគីកូរ៉េ ។ ភាគីកូរ៉េ បានសន្យាថានឹងបន្តជំរុញឱ្យ ទីភ្នាក់ងារ KOICA និងសម្របសម្រួលជាមួយរដ្ឋាភិបាលរបស់ខ្លួន ដើម្បីជួយគាំទ្រដល់គម្រោងរបស់ អ.ជ.ប.គ.ញ ។
- បានរៀបចំពិធីប្រគល់-ទទួល មធ្យោបាយ សម្ភារៈ សម្រាប់ការិយាល័យទំនាក់ទំនងព្រំដែននៃច្រកទ្វារអន្តរជាតិត្រពាំងផ្លុង (ខេត្តកំពង់ចាម) ច្រកទ្វារអន្តរជាតិ ភ្នំដិន (ខេត្តតាកែវ) និងមធ្យោបាយសម្ភារៈសម្រាប់ការិយាល័យគណៈកម្មការប្រឹក្សាយោបល់ (C-PAC) នៃគម្រោងស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (PATROL) របស់អង្គការ UNODC ដែលគិតជាទឹកប្រាក់ស្មើនឹង ៦៦.២៦៧,៥០ ដុល្លារសហរដ្ឋអាមេរិក កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១១ ។

***នៅក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ៖*

- បានទៅចូលរួមកិច្ចប្រជុំ ទ្វេភាគី/ត្រីភាគី កម្ពុជា-ឡាវ-វៀតណាម លើកទី១១ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងវៀងចន្ទ័ ប្រទេសឡាវ ពីថ្ងៃទី១៤-១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ដឹកនាំដោយ ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ) ។
- បានទៅចូលរួមសិក្ខាសាលា និងសន្និសីទ ស្តីពីការអភិវឌ្ឍន៍ដំណាំជំនួស នៅខេត្តឈៀងរ៉ៃ និង ខេត្តឈៀងម៉ៃ ប្រទេសថៃ (០៦-១១/១១/២០១១) ។

*-ការងារផ្សេងៗ*

ដើម្បីបំពេញឱ្យការអនុវត្តទិសដៅសកម្មភាពពហុវិស័យខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តការងារមួយចំនួនទៀត មានដូចខាងក្រោម :

១. បានរៀបចំក្រុមការងារទៅចូលរួមប្រជុំពន្យល់ សេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាមួយគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ នៃរដ្ឋសភា ។

២. បានស្នើសុំគោលការណ៍សម្រេចដ៏ខ្ពង់ខ្ពស់ពីសម្តេចនាយករដ្ឋមន្ត្រី លើសំណើសុំកែសម្រួលចំណុចមួយចំនួននៃសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ នៃរដ្ឋសភា ។

៣. បានអញ្ជើញជាតំណាងរាជរដ្ឋាភិបាល ទៅចូលរួមប្រជុំដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ នៅវិមានរដ្ឋសភា (ដឹកនាំដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន) ។

៤. បានដឹកនាំកិច្ចប្រជុំគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តព្រំដែន កម្ពុជា-ឡាវ នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី (ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ) ។

៥. បានអញ្ជើញជាអធិបតី ដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ) នៅក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារ ឆ្នាំ២០១២ របស់ខេត្តបន្ទាយមានជ័យ ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ក្នុងខែវិច្ឆិកានេះ ដោយមានការចូលរួមពីក្រសួង-ស្ថាប័នពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធគ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជននានា ធ្វើឱ្យការអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង ៥ ក្នុងការត្រួតពិនិត្យគ្រឿងញៀន ទទួលបានលទ្ធផលល្អប្រសើរ ។ ប៉ុន្តែទោះជាយ៉ាងណា លើការងារកាត់បន្ថយតម្រូវការគ្រឿងញៀន យើងបានវាយតម្លៃថា នៅមិនទាន់បានគ្របដណ្តប់បានមួយរយភាគរយទៅលើក្រុមគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់នៅឡើយ ។ ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទោះបីមន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋានបានខិតខំបង្ក្រាបយ៉ាងសកម្ម យ៉ាងណាក៏ដោយ ក៏នៅតែមានសញ្ញាគួរកត់សំគាល់នៅឡើងចំពោះបទល្មើសតូចតាច ។ ការមិនទាន់បានរៀបចំសេវាព្យាបាលអ្នកញៀននៅតាមសហគមន៍ឱ្យដំណើរការទៅដោយរលូន បានធ្វើឱ្យសមត្ថកិច្ចមានការលំបាកក្នុងការអនុវត្តច្បាប់ ពោលគឺវិធានការព្យាបាលដោយចាប់បង្ខំ និងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ។ យើងបានចុះទៅធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅតាមខេត្តគោលដៅមួយចំនួន ជាពិសេស បណ្តាខេត្តនៅតាមតំបន់ព្រំដែន ដែលសមត្ថភាពមន្ត្រីនៅទីនោះនៅមានកម្រិតនៅឡើយ ប៉ុន្តែយើងនៅមិនទាន់អាចវាស់ស្ទង់បានពីកម្រិតយល់ដឹងរបស់ពួកគាត់នៅឡើយ ។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ យើងបានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបានច្រើនជាមួយបណ្តាប្រទេស និងអង្គការជាដៃគូអភិវឌ្ឍន៍ ប៉ុន្តែប្រទេសមួយចំនួននៅតែមិនបានចាត់ទុកបញ្ហាគ្រឿងញៀនជាអាទិភាពសម្រាប់ផ្តល់ការគាំទ្រដល់កម្ពុជា ដែលធ្វើឱ្យគម្រោងកម្មវិធីមួយចំនួន ដែលបានសន្យាផ្តល់មិនទាន់បានដំណើរការតាមការគ្រោងទុក ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែ ធ្នូ ឆ្នាំ ២០១១

ដើម្បីធ្វើឱ្យមាននិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវទិសដៅសកម្មភាពមួយចំនួនដូចខាងក្រោម ៖

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន នឹងអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តគោលដៅមួយក្នុងចំណោមខេត្តគោលដៅនានា ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN ស្តីពី សកម្មភាពនិងលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់ខេត្ត ។

១.២. ត្រៀមរៀបចំផែនការសកម្មភាព សម្រាប់ការរៀបចំវេទិកា សំណួរ-ចម្លើយ សម្រាប់សិស្ស និស្សិត វិទ្យាល័យ និងមហាវិទ្យាល័យ ដើម្បីបង្កើនចំណេះដឹងពីបញ្ហាគ្រឿងញៀន តាមប្រព័ន្ធផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាបន័នានា ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រឿងញៀន តាមប្រពន្ធ័ផ្សព្វផ្សាយរដ្ឋ និង ឯកជន និងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាបន័នានា ក្នុងការចុះទៅបណ្តុះបណ្តាលផ្សព្វផ្សាយអប់រំផ្ទាល់នៅតាមសហគមន៍ជាតិ រួមទាំងបន្តជំរុញរាជធានី-ខេត្ត ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំជាប្រចាំ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

១.៤. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន / អេដស៍ នៅខេត្តបាត់ដំបង ថ្ងៃទី០៥-០៦ ខែធ្នូ ឆ្នាំ២០១១ និងនៅខេត្ត កំពង់ចាម នៅចុងខែ ធ្នូ។

១.៥. ត្រៀមរៀបចំវគ្គផ្សព្វផ្សាយអប់រំអំពីបញ្ហាគ្រឿងញៀនដល់ពិធីករ និងសិល្បៈករ នានា ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត និង អង្គការ UNODC តាមរយៈគម្រោង PATROL ដើម្បីពិនិត្យលទ្ធភាពពង្រឹងការងារ BLO ។

២.២. បន្តកិច្ចសហការជាមួយអង្គការ UNODC អនុតំបន់ ដើម្បីរៀបចំផែនការសកម្មភាពគម្រោង PATROL សម្រាប់ឆ្នាំ២០១២ និង រៀបចំពិធីប្រគល់-ទទួល មធ្យោបាយ សម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន (BLO) ច្រកទ្វារអន្តរជាតិ ភ្នំដិន (ខេត្តតាកែវ) នៅសប្តាហ៍ទី៣ ខែធ្នូ ឆ្នាំ២០១១ ។

២.៣. បន្តកិច្ចសហការជាមួយអង្គការ UNODC ក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) ។

២.៤. ត្រៀមចូលរួមសកម្មភាពរបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ ។

### ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គម-

កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ) ដើម្បីជំរុញការងារសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ស្នើសុំទៅភាគីវៀតណាម តាមរយៈកិច្ចប្រជុំគណៈកម្មការចម្រុះទ្វេភាគី កម្ពុជា-វៀតណាម លើកទី១២ ។

៣.២. បន្តសហការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានការអនុវត្តកម្មវិធីប្រចាំថ្ងៃនៅតាមមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋនិងឯកជន ។

៣.៣. បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការរៀបចំបង្កើតសេវាសុខភាពផ្លូវចិត្តនិងគ្រឿងញៀន នៅ ខេត្តស្ទឹងត្រែង និង ខេត្តក្រចេះ ដើម្បីចូលរួមអនុវត្តផែនការសកម្មភាពរបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនឡាវ ។

៣.៤. បន្តសហការសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ ដើម្បីជំរុញការរៀបចំលិខិតបទដ្ឋានគតិយុត្តិនានា ពាក់ព័ន្ធនឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

៤.១. ត្រៀមបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ នៅខេត្តពោធិ៍សាត់ និង ខេត្តឧត្តរមានជ័យ ។

៤.២. បន្តកិច្ចសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ចាម ខេត្តតាកែវ និងខេត្តកំពត ដើម្បីធ្វើការសិក្សាប្រមូលព័ត៌មានពាក់ព័ន្ធនឹងការចរាចរ ការប្រើប្រាស់សារធាតុគីមី ។

៤.៣. បន្តការរៀបចំកែសម្រួល តួនាទី ភារកិច្ច សមាសភាព របស់ការិយាល័យទំនាក់ ទំនងព្រំដែន (BLO) ទាំង ១៤ កន្លែង នៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ កម្ពុជា-វៀតណាម និង កម្ពុជា-ឡាវ ។

៤.៤. ត្រៀមរៀបចំកិច្ចប្រជុំត្រៀម ការបណ្តុះបណ្តាលគ្រូបង្គោលតាមសាលាភូមិភាគ របស់បណ្ឌិត្យសភានគរបាលកម្ពុជា ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ នៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម នៅប្រទេសឡាវ ថ្ងៃទី០៦-១០ ខែធ្នូ ឆ្នាំ២០១១។

៥.២. ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ទ្វេភាគី កម្ពុជា-ថៃ លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នាថ្ងៃទី៣០ខែវិច្ឆិកា ដល់ ថ្ងៃទី០៣ខែធ្នូឆ្នាំ២០១១ នៅខេត្តព្រះសីហនុ ។

៥.៣. ត្រៀមទៅទស្សនកិច្ចសិក្សាស្តីពីការប្រមូលទិន្នន័យគ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២១-២២ ខែ ធ្នូ ឆ្នាំ ២០១១ នៅប្រទេសសឹង្ហបុរី ។

៥.៤. ត្រៀមទៅចូលរួមសន្និសីទស្តីពីគោលនយោបាយអាកុល សកល ឆ្នាំ២០១១ "ស្តីពីយុទ្ធសាស្ត្រអាកុលសកល ទៅជាសកម្មភាពថ្នាក់ជាតិ និងក្នុងស្រុក និង កិច្ចប្រជុំភាពជាដៃគូ SEA RO III នៅទីក្រុងបាងកក ប្រទេសថៃ ថ្ងៃទី២៨ ខែវិច្ឆិកា ដល់ ថ្ងៃទី ០៣ ខែធ្នូ ២០១១ ។

៩.៩. ត្រៀមចូលរួមកិច្ចប្រជុំ Inter-Sessional Support Group Meeting on Confidence-Building Measures and Preventive Diplomacy នាថ្ងៃទី ០៧-០៨ ខែ ធ្នូ ឆ្នាំ ២០១១ នៅសណ្ឋាគារភ្នំពេញ តាមការអញ្ជើញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ក្រៅពីទិសដៅសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រពហុវិស័យទាំង ៥ ដូចជា ៖

- បន្តការតាមដាន និងសហការជាមួយស្ថាប័ននីតិបញ្ញត្តិលើសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានចូលរួមប្រជុំដើម្បីការពារ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។
- ត្រៀមចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់បណ្តាខេត្តជាប់ព្រំដែនភាគឦសាន ។
- បន្តជំរុញការរៀបចំផែនការជាតិ៥ឆ្នាំ លើកទី២ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- បន្តជំរុញការរៀបចំសាលាបៃតង ដើម្បីផ្សព្វផ្សាយ និងអនុវត្តនៅឆ្នាំ២០១២ ខាងមុខ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អជបគញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អជបគញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ

| ល.រ | ខ្លឹមសារ និង គោលដៅ |
|---|---|
| ១ | ការស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពីសម្តេចនាយករដ្ឋមន្ត្រី លើសំណើកែសម្រួលចំណុចមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន របស់គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត បោសសំអាត និងមុខងារសាធារណៈ នៃរដ្ឋសភា (លិខិតលេខ ១០៧.១១ លស ចុះហត្ថលេខាថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១ ដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ) |
| | ការដឹកនាំប្រជុំគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនកម្ពុជា ឡាវ<br>(ដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ថ្ងៃទី ២៧/១០/២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី) |
| | ការណែនាំឲ្យចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ នៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម (**CLV**) និងកិច្ចប្រជុំពាក់ពន្ធ័ នៅប្រទេសឡាវ (ដឹកនាំដោយឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ ថ្ងៃទី ០៦-១០ ខែធ្នូ ឆ្នាំ២០១១) |
| | បានអនុញ្ញាតជាគោលការណ៍ឲ្យប្រើប្រាស់នូវកម្មវិធីបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ស្តីពី យុទ្ធសាស្រ្តប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន |
| | ការណែនាំឲ្យសហការជាមួយសាលារាជធានីភ្នំពេញ កែសម្រួលផ្ទាំងរូបភាព (រូបសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដុតកម្ទេចដំណាំកញ្ឆា) និងបន្ថែមរូបភាពលោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត និងពាក្យស្លោកផ្សព្វផ្សាយអប់រំពីគ្រឿងញៀន |
| | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន ចូលរួមរៀបចំពិព័រណ៌រូបអបអរសាទរខួប ២០ ឆ្នាំនៃការយាងនិវត្តន៍មកកាន់មាតុប្រទេសរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ និងព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះអង្គគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ទិវាកំណើតកងយោធពលខេមរភូមិន្ទ និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក |
| | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ទ្វេភាគី កម្ពុជា-ថៃ លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ, ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៣០ ខែវិច្ឆិកា -០៣ ខែធ្នូ ឆ្នាំ២០១១ |
| | បានណែនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំវគ្គផ្សព្វផ្សាយចំណេះដឹងជាមូលដ្ឋានពីគ្រឿងញៀន ដល់លេខាធិការដ្ឋានគ្រឿងញៀនរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី ខេត្ត និង នាយកវិទ្យាល័យនៅតាមរាជធានី ខេត្ត នៅទូទាំងប្រទេស |
| | បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១១ និងលើកទិសដៅការងារឆ្នាំ២០១២ របស់ខេត្តបន្ទាយមានជ័យ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ (ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ) |
| | បានចូលរួមប្រជុំដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅវិមានរដ្ឋសភា ថ្ងៃទី២៥/១១/២០១១ (ដឹកនាំដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ។ សមាជិករាជរដ្ឋាភិបាល មាន ឯ.ឧ កែ គឹមយ៉ាន, ឯ.ឧ តេង សាវង្ស, ឯ.ឧ ហ៊ី សោភា, ឯ.ឧ ជូ យិនស៊ីម, ឯ.ឧ អ៊ិត ប្រាំង ។ មន្ត្រីជំនាញ មាន ឯ.ឧ មាស វិរិទ្ធ, ឯ.ឧ កើត រិទ្ធ, លោក ខៀវ សាម៉ន, លោក ឯម ហ៊ីយ ។ |

## សកម្មភាពផ្សព្វផ្សាយអប់រំ របស់រាជធានី-ខេត្ត ប្រចាំខែ វិច្ឆិកា ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាប័ន | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | -បានរៀបចំពិព័រណ៌រូបភាពអបអរសាទរបុណ្យខួប ២០ ឆ្នាំនៃការយាងនិវត្តន៍មកកាន់មាតុប្រទេសរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រជាតិខ្មែរ ព្រះរាជពិធីបុណ្យចំរើនព្រះជន្មថ្វាយព្រះអង្គគម្រប់ ៨៩ យាងចូល ៩០ ព្រះវស្សា ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា ទិវាកំណើតកងយោធពលខេមរភូមិ្ទ និងបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ។<br>-បានធ្វើការកែសម្រួលផ្ទាំងរូបសម្តេចនាយករដ្ឋមន្ត្រីដុតកម្ទេចដំណាំកញ្ឆា និងបន្ថែមរូបលោកជំទាវគតិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន និងសារអប់រំពីគ្រឿងញៀន ដែលតាំងនៅខាងលិចគល់ស្ពានជ្រោយចង្វា ។<br>-បានរៀបចំវគ្គបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋានអំពីគ្រឿងញៀន ដល់ប្រធាន-អនុប្រធាន លេខាធិ-ការដ្ឋានគ្រឿងញៀនរាជធានី ខេត្ត ប្រធាន-អនុប្រធានមន្ទីរអប់រំយុវជន និងកីឡារាជធានី-ខេត្ត នាយកនាយករងវិទ្យាល័យ និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ (២៤/១១/២០១១) សរុបចំនួន <u>**១៤០**</u> នាក់ ។<br>-បានអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តមណ្ឌលគីរី ដើម្បីផ្តល់បទសម្ភាសន៍នៅស្ថានីយ | ១៤០ នាក់ |

| | | | |
|---|---|---|---|
| | | ទូរទស្សន៍ ស៊ី.ធី.អិន ស្តីពីលទ្ធផលនិងការទទួលខុសត្រូវលើការងារត្រួតពិនិត្យគ្រឿងញៀនរបស់ខេត្ត<br>-បានចូលរួមប្រជុំដើម្បីការពារសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៅវិមានរដ្ឋសភា កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១ ។ | |
| ២ | ក្រចេះ | -អាជ្ញាធរស្រុកឆ្លូង បានចុះផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់ប្រជាពលរដ្ឋចំនួន <u>**៤១៥**</u> នាក់ (ស្រី ២១០ នាក់), សប្តាហ៍ទីបួន <u>**១១៥**</u> នាក់ (ស្រី ៦៥ នាក់) | ៥៣០ នាក់ |
| ៣ | ព្រះវិហារ | -អាជ្ញាធរស្រុកសង្គមថ្មី ស្រុកត្បែងមានជ័យ ស្រុកជ័យសែន ស្រុកគូលែន បានបញ្ជ្រាបការផ្សព្វផ្សាយនៅក្នុងឱកាសផ្សព្វផ្សាយ គោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាព ចំនួន ៤ លើក មានអ្នកចូលរួម ចំនួន <u>**១.២៨០**</u> នាក់ / ស្រី ៦៥៥ នាក់, សប្តាហ៍ទី១ខែវិច្ឆិកា ៦លើក(ក្នុងស្រុកខាងលើ) <u>**១.៦១៤**</u> នាក់ / ស្រី ៩៦៨ នាក់ | ២.៨៩៤ នាក់ |
| ៤ | តាកែវ | -អាជ្ញាធរស្រុកត្រាំកក់ បានចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅឃុំចំនួន ៣ មានប្រជាពលរដ្ឋចូលរួម ចំនួន <u>**៦០១**</u> នាក់ (ស្រី ២៧២ នាក់)<br>-អធិការដ្ឋាននគរបាលស្រុកទ្រាំង និង ស្រុកបុរីជលសារ បានចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមទីវត្តអារាម ចំនួន ៣៥ លើក = <u>**១៩១**</u> នាក់ / ស្រី ៩៦ នាក់ (របាយការណ៍របស់ខេត្ត) | ៧៩២ នាក់ |
| ៥ | ស្វាយរៀង | -ស្នងការដ្ឋាននគរបាលខេត្តបានចុះផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ៦៨ លើក មានអ្នកចូលរួម <u>**៥.០២៣**</u> នាក់ / ស្រី ២.១៥៦ នាក់ | ៥.០២៣ នាក់ |
| ៦ | បាត់ដំបង | -អាជ្ញាធរស្រុកថ្មគោល បានចុះផ្សព្វផ្សាយអំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ៩ លើកដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅតាមសហគមន៍ ចំនួន <u>**៥.១០៤**</u> នាក់ / ស្រី ២.១២៥ នាក់<br>-អាជ្ញាធរស្រុកសំពៅលូន បានចុះផ្សព្វផ្សាយអប់រំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋនៅតាមសហគមន៍ ចំនួន ៦ លើក មានអ្នកចូលរួមចំនួន <u>**២០១**</u> នាក់ / ស្រី ១៤៩ នាក់ (របក ខែវិច្ឆិកា ២០១១ របស់ខេត្តបាត់ដំបង) | ៥.៣០៥ នាក់ |
| ៧ | កំពង់ស្ពឺ | -ស្នងការដ្ឋាននគរបាលខេត្ត ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល ស្រុកឧដុង្គ ចំនួន១៥ប៉ុស្តិ៍= <u>**២៧**</u> នាក់<br>-ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ក្នុងស្រុកថ្ពង ៥ លើក ដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ = <u>**៥០៩**</u> នាក់ / ស្រី ១១១ នាក់, នៅស្រុកសំរោងទង ១ លើក ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ សរុប <u>**១.៥៣៨**</u> នាក់ / ស្រី ៥៣១ នាក់ (តាមរបាយការណ៍របស់ខេត្ត) | ២.០៧៤ នាក់ |
| ៨ | កំពង់ចាម | -លេខាធិការដ្ឋានគ្រឿងញៀន បានចុះផ្សព្វផ្សាយច្បាប់ និងផលប៉ះពាល់នៃគ្រឿងញៀន នៅស្រុកព្រៃឈរ ដល់ប្រជាពលរដ្ឋ ១ លើក = ២៧៨ នាក់ / ស្រី ១៥ នាក់, នៅស្រុកកំពង់សៀម ១ លើក = ៧៤ នាក់ / ស្រី ៥ នាក់ និងបានចែកឯកសារផ្សព្វផ្សាយ តាមផ្ទះសំណាក់ និង កន្លែងខារ៉ាអូខេ(របាយការណ៍ខេត្ត) | ៣៥២ |
| សរុប | | | **១.៧១១០ នាក់** |

## បទល្មើសគ្រឿងញៀនដែលបង្ក្រាប ក្នុងខែ វិច្ឆិកា ឆ្នាំ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ដឹកជញ្ជូន ជួញដូរ | | | ផលិត | | | ដាំដុះ ចម្រាញ់ប្រែងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ចំនួនដីកា | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **6** | **19** | **5** | 6 | 19 | 5 | | | | | | | | | | | | |
| 2 | ន.ប ភ្នំពេញ | **13** | **26** | **3** | 13 | 25 | 2 | | | | | | | | | | 1 | 1 | 1 |
| 3 | ន.ប កំពង់ចាម | **4** | **10** | **0** | 4 | 10 | 0 | | | | | | | | | | | | |
| 4 | ន.ប ព្រះសីហនុ | **2** | **5** | **1** | 1 | 1 | 1 | | | | | | | 1 | 4 | 0 | | | |
| 5 | ន.ប ស្ទឹងត្រែង | **2** | **5** | **1** | 2 | 5 | 1 | | | | | | | | | | | | |
| 6 | ន.ប ព្រះវិហារ | **0** | **1** | **0** | | | | | | | | | | | | | 1 | 1 | 0 |
| 7 | ន.ប បាត់ដំបង | **3** | **6** | **4** | 3 | 6 | 4 | | | | | | | | | | | | |
| 8 | ន.ប កោះកុង | **0** | **1** | **1** | | | | | | | | | | | | | 1 | 1 | 1 |
| 9 | ន.ប បន្ទាយមានជ័យ | **1** | **4** | **2** | 1 | 4 | 2 | | | | | | | | | | | | |
| 10 | ន.ប ប៉ៃលិន | **0** | **1** | **0** | | | | | | | | | | | | | 1 | 1 | 0 |
| | **សរុប** | <u>**31**</u> | **78** | **17** | <u>**30**</u> | 70 | 15 | | | | | | | <u>**1**</u> | 4 | 0 | **4** | 4 | 2 |

## វត្ថុតាងគ្រឿងញៀន ចាប់យក ប្រចាំខែ វិច្ឆកា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)

| ល | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក |
|---|---|---|

| រ | | *WY* (គ្រាប់) | *ICE* (ក្រាម) | *Heroine* (ក្រាម) | ដើមកញ្ឆា ម² | កញ្ឆាក្រៀម (ក្រាម) | *Ecstasy* (គ្រាប់) | *Pseudo-Ephedrine* | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
|---|---|---|---|---|---|---|---|---|---|---|
| *1* | មន្ទីរប្រឆាំងគ្រឿងញៀន | *6.022* | *1.355,4* | | | | | | | |
| *2* | ន.ប ភ្នំពេញ | *2 ½* | *8,48* | | | | | | | |
| *3* | ន.ប កំពង់ចាម | | *2,29* | | | | | | | |
| *4* | ន.ប ព្រះសីហនុ | | *3,8* | | | | | | | |
| *5* | ន.ប ស្ទឹងត្រែង | *175 ½* | *1,56* | | | | | | | |
| *6* | ន.ប ព្រះវិហារ | | | | | | | | | |
| *7* | ន.ប បាត់ដំបង | *52* | *0,3* | | | | | | | |
| *8* | ន.ប កោះកុង | | | | | | | | | |
| *9* | ន.ប បន្ទាយមានជ័យ | *16* | | | | | | | | |
| *10* | ន.ប ប៉ៃលិន | | | | | | | | | |
| | សរុប | ***6.268*** | ***1.371,83*** | | | | | | | |

## ទ្រព្យសម្បត្តិ និងវត្ថុតាងផ្សេងៗ ពាក់ពន្ធ័បទល្មើសគ្រឿងញៀន

-មន្ទីរប្រឆាំង គ្រ.ញ — ម្សៅកេតាមីន ០,៩ ក្រាម, ម្សៅពណ៌ផ្កាឈូក ១ ក្រាម, ជញ្ជីង ៣, កាំភ្លើងវែង ២ ដើម, ម៉ាស៊ីនថតសម្លេង១, រូបបដិមាករ ១ អង្គ, ម៉ូតូ ៣ គ្រឿង, រថយន្ត ៤ គ្រឿង, ប្រាក់ ២១ ដុល្លារ ស.រ.អា, សម្ភារៈ ឯកសណ្ឋានមន្ត្រីយោធាជាន់ខ្ពស់ មួយចំនួន

-ន.ប ភ្នំពេញ — ម្សៅពណ៌សសង្ស័យគ្រឿងញៀន ៦,៦៤ ក្រាម, ជញ្ជីង ២, ម៉ូតូ ៧ គ្រឿង, ប្រាក់ ២៤០.០០០ រៀល, ២១ ដុល្លារ ស.រ.អា

-ន.ប កំពង់ចាម — រថយន្ត ១ គ្រឿង

-ន.ប ព្រះសីហនុ — ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន

-ន.ប បាត់ដំបង — ជញ្ជីង ១